ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋាននៃ
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## គម្រោងអាហារូបត្ថម្ភនៅកម្ពុជា - ២ ( P177370 )

# ផែនការអនុវត្ត
# សុវត្ថិភាពសង្គម និងបរិស្ថាន

DRAFT FOR CONSULTATIONS

ខែធ្នូ ឆ្នាំ២០២១

# ផែនការអនុវត្តសុវត្ថិភាពសង្គម និងបរិស្ថាន

1. ព្រះរាជាណាចក្រកម្ពុជា ដែលតទៅហៅថា (អ្នកទទួល) នឹងអនុវត្តគម្រោងអាហាររូបបត្ថម្ភដំណាក់កាលទី២ ដែលតទៅហៅថា (គម្រោង) ដោយមានការចូលរួមអនុវត្តពីលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(លេខាធិការដ្ឋាន គ.ជ.អ.ប) ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងសុខាភិបាល រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ សមាគមអភិវឌ្ឍន៍អន្តរជាតិ ដែលដើរតួជាម្ចាស់មូលនិធិរបស់ KfW (Kreditanstalt für Wiederaufbau) ដែលតទៅហៅថា (ធនាគារ) បានយល់ព្រមផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងនេះ។
2. អ្នកទទួល នឹងអនុវត្តវិធានការ និងមធ្យោបាយនានា ដើម្បីធានាថា ការអនុវត្តគម្រោងស្របតាមស្តង់ដារសុវត្ថិភាពសង្គម និងបរិស្ថាន។ ផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាននេះ បានចង្អុលបង្ហាញដោយសង្ខេបអំពីវិធានការ និងមធ្យោបាយនានា ឯកសារ ឬផែនការជាក់លាក់ ព្រមទាំងពេលវេលានៃការវិធានការ និងសកម្មភាពនីមួយៗ។
3. អ្នកទទួលក៏នឹងអនុវត្តតាមបទប្បញ្ញត្តិនៃឯកសារសុវត្ថិភាពសង្គម និងបរិស្ថានផ្សេងៗទៀត ដែលជាលក្ខខណ្ឌតម្រូវក្រោមក្របខ័ណ្ឌសុវត្ថិភាពសង្គម និងបរិស្ថាន (ESF) ដែលត្រូវបានកំណត់នៅក្នុងផែនការអនុវត្តសុវត្ថិភាពសង្គម និងបរិស្ថាន (ESCP) នេះ ដូចជាផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) នីតិវិធីគ្រប់គ្រងការងារ(LMP) និងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) និងការកំណត់ពេលវេលាដែលបានបញ្ជាក់នៅក្នុងឯកសារសុវត្ថិភាពសង្គម និងបរិស្ថាន (E&S) ទាំងនោះ។
4. អ្នកទទួល ត្រូវទទួលខុសត្រូវចំពោះការអនុលោមតាមតម្រូវការទាំងអស់ដែលបានកំណត់ក្នុងផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាន (ESCP) រួមទាំងការអនុវត្តវិធានការ និងសកម្មភាពជាក់លាក់ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនានា ដូចដែលបានកំណត់ក្នុងចំណុចទី១ខាងលើ។
5. អ្នកទទួល ត្រូវអនុវត្តវិធានការ សកម្មភាពនានា និងត្រូវរាយការណ៍ទៅធនាគា ដូចដែលមានចែងក្នុងផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាន (ESCP)នេះ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ហើយធនាគារនឹងតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តក្នុងរយៈពេលនៃការអនុវត្តគម្រោងទាំងមូល។

DRAFT FOR CONSULTATIONS

6. ដូចដែលបានព្រមព្រៀងដោយធនាគារ និងអ្នកទទួល ផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាន (ESCP) នេះអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ដើម្បីឆ្លុះបញ្ចាំងពីការគ្រប់គ្រងការអនុវត្តគម្រោង ការផ្លាស់ប្តូរឱ្យស្របទៅនឹងស្ថានភាពដែលមិនអាចប៉ាន់ស្មានជាមុនបាន ឬដើម្បីឆ្លើយតបទៅនឹងលទ្ធផលនៃការវាយតម្លៃការអនុវត្តគម្រោងដែលធ្វើឡើងក្រោមផែនការសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាននេះ។ ដូច្នេះ អ្នកទទួលត្រូវយល់ព្រមជាមួយធនាគារ ដើម្បីផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពផែនការសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថានរបស់ខ្លួនឱ្យស្របតាមការផ្លាស់ប្តូរនេះ។ កិច្ចព្រមព្រៀងស្តីពីការផ្លាស់ប្តូរផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាន (ESCP) ត្រូវធ្វើឡើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារវាងធនាគារ និងអ្នកទទួល។ អ្នកទទួលត្រូវផ្សព្វផ្សាយអំពីផែនការអនុវត្តសម្រាប់សុវត្ថិភាពសង្គម និងបរិស្ថាន (ESCP) ដែលបានធ្វើបច្ចុប្បន្នភាព។

7. នៅពេលដែលគម្រោងមានការផ្លាស់ប្តូរ មានស្ថានភាពកើតឡើងដែលមិនអាចប្រមើលមើលឃើញទុកជាមុនបាន ឬលទ្ធផលនៃការអនុវត្តគម្រោងដែលមានការផ្លាស់ប្តូរអំពីហានិភ័យ និងផលប៉ះពាល់ក្នុងអំឡុងពេលអនុវត្តគម្រោង នោះអ្នកទទួលត្រូវផ្តល់មូលនិធិបន្ថែម (តាមការចាំបាច់) ដើម្បីចាត់វិធានការនានាដោះស្រាយ និងឆ្លើយតបនឹងហានិភ័យ និងផលប៉ះពាល់ទាំងនោះ។

DRAFT FOR CONSULTATIONS

| វិធានការ ឬសកម្មភាព | | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| **ការត្រួតពិនិត្យ និងរបាយការណ៍** | | | |
| ក | **ការរាយការណ៍ជាទៀងទាត់**<br>រៀបចំ និងដាក់ជូននូវរបាយការណ៍ត្រួតពិនិត្យផ្នែកសង្គម និងបរិស្ថានជាទៀងទាត់ ដែលជាផ្នែកមួយនៃរបាយការណ៍គម្រោងពាក់កណ្តាលឆ្នាំស្តីពីការអនុលោមតាមវិធានការសុវត្ថិភាពបរិស្ថាន និងសង្គមទាំងមូល ដែលបានកំណត់នៅក្នុងផែនការអនុវត្តសុវត្ថិភាពសង្គម និងបរិស្ថាន (ESCP), ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) នីតិវិធីគ្រប់គ្រងការងារ (LMP) និងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) | រាល់៦ខែម្តង | លេខាធិការដ្ឋាន គ.ជ.អ.ប |
| ខ | **តាមឧប្បត្តិហេតុ និងគ្រោះថ្នាក់នានា**<br>ជូនដំណឹងភ្លាមៗ (ក្នុងរយៈពេល២៤ម៉ោង) ដល់ធនាគារអំពីឧប្បត្តិហេតុ ឬគ្រោះថ្នាក់ណាមួយដែលទាក់ទងនឹងការអនុវត្តគម្រោង ឬទំនងជាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបរិស្ថាន សហគមន៍ និងបុគ្គលិកគម្រោង។ ឧបទ្ទវហេតុ ឬគ្រោះថ្នាក់បែបនេះរួមបញ្ចូលទាំង ការប្រឈមនឹងការឆ្លងជំងឺ COVID-19 ដោយសារសកម្មភាពអនុវត្តគម្រោង គ្រោះថ្នាក់នៅកន្លែងធ្វើការ ការចោទប្រកាន់អំពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន ឬការបៀតបៀនផ្លូវភេទ (SEA/SH) អំពើហិង្សាប្រឆាំងនឹងកុមារ (VAC) និងការប្រព្រឹត្តមិនត្រឹមត្រូវផ្នែកវេជ្ជសាស្ត្រដែលទាក់ទងនឹងសកម្មភាពគម្រោង។ ផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ទាក់ទងនឹងឧបទ្ទវហេតុ ឬគ្រោះថ្នាក់ទាំងនេះ ដោយបង្ហាញពីវិធានការភ្លាមៗដែលបានធ្វើឡើង និងឬអ្វីដែលគ្រោងនឹងធ្វើ | ជូនដំណឹងដល់ធនាគារភ្លាមៗអំពីឧប្បត្តិហេតុឬគ្រោះថ្នាក់ក្នុងរយៈពេល 24 ម៉ោងបន្ទាប់ពីដឹងពីឧប្បត្តិហេតុ ឬគ្រោះថ្នាក់នោះ។ របាយការណ៍ នឹងត្រូវបានផ្តល់ជូននៅក្នុងរយៈពេលមួយដែលអាចទទួលយកបានទៅធនាគារតាមការស្នើសុំ។ តាមដានហានិភ័យដែល | លេខាធិការដ្ឋាន គ.ជ.អ.ប |

DRAFT FOR CONSULTATION



Confidential

| វិធានការ ឬសកម្មភាព | | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| | ដើម្បីដោះស្រាយ។ រៀបចំរបាយការណ៍ស្តីពីឧបទ្ទវហេតុ ឬគ្រោះថ្នាក់ ហើយស្នើវិធានការណាមួយ ដើម្បីទប់ស្កាត់ការកើតឡើងវិញ។ | អាចកើតមាន និងនីតិវិធីពាក់ព័ន្ធ ក្នុងរយៈពេលនៃការអនុវត្តគម្រោងទាំងមូល។ | |
| ESS 1៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់នៃបរិស្ថាន និងសង្គម | | | |
| 1.1. | **រចនាសម្ព័ន្ធស្ថាប័ន**<br>ចាត់តាំងជនបង្គោលបរិស្ថានមួយរូប និងជនបង្គោលសង្គមមួយរូប និង/ឬ អ្នកឯកទេស ដើម្បីត្រួតពិនិត្យការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងក្របខ័ណ្ឌនៃការអនុវត្តគម្រោង។ | One month following project effectiveness | លេខាធិការដ្ឋាន គ.ជ.អ.ប |
| 1.2 | **ការគ្រប់គ្រងបរិស្ថាន និងសង្គម**<br>អនុម័ត និងអនុវត្ត ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) នីតិវិធីគ្រប់គ្រងការងារ (LMP) ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) ដែលត្រូវបានរៀបចំសម្រាប់គម្រោងក្នុងលក្ខណៈដែលធនាគារអាចទទួលយកបាន។ ទាំងនេះរួមបញ្ចូលជាមួយនឹងឧបករណ៍ សម្ភារផ្សេងៗទៀត ដូចជា i) ការអនុវត្តពិធីសារ និងនីតិវិធីពាក់ព័ន្ធ ដើម្បីជៀសវាង និងកាត់បន្ថយហានិភ័យ និងវិធានការនានា ដើម្បីបង្កើនឱកាសសម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន ii) ត្រួតពិនិត្យហានិភ័យដែលអាចកើតមានក្នុងអំឡុងពេលអនុវត្តគម្រោង iii) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការ | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) នីតិវិធីគ្រប់គ្រងការងារ (LMP) ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) នឹងត្រូវផ្សព្វផ្សាយ ពិគ្រោះយោបល់ និងរៀបចំបញ្ចប់ មុនពេល | លេខាធិការដ្ឋាន គ.ជ.អ.ប |

DRAFT FOR CONSULTATIONS



Confidential

| វិធានការ ឬសកម្មភាព | | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| | សម្របសម្រួលដល់អង្គភាពអនុវត្ត iv) យកចិត្តទុកដាក់ និងតាមដានលើការប្តឹងតវ៉ានានាពាក់ព័ន្ធនឹងការអនុវត្តគម្រោង v) អនុវត្ត និងរក្សាការចូលរួមរបស់ភាគីពាក់ព័ន្ធ។ ធ្វើបច្ចុប្បន្នភាពឧបករណ៍ទាំងនេះ ប្រសិនបើមានការផ្លាស់ប្តូរក្នុងការរៀបចំ ការអនុវត្តសកម្មភាព និង/ឬហានិភ័យរបស់គម្រោង។ | ការអនុវតម៉ែត និងការអនុវត្តគម្រោង។ | |
| ESS 2: ពលកម្ម និងលក្ខខណ្ឌការងារ | | | |
| 2.1 | **និតិវិធីគ្រប់គ្រងការងារ**<br>ទទួលយក និងអនុវត្តនីតិវិធីគ្រប់គ្រងការងារ (LMP) ដែលត្រូវបានបង្កើតឡើងសម្រាប់គម្រោង ជាពិសេសលើទិដ្ឋភាពទាក់ទងនឹងការងារ សុខភាព និងសុវត្ថិភាព (OHS) ក្នុងអំឡុងពេលជំងឺរាតត្បាតជំងឺ COVID-19 និងការព្យាបាលប្រកបដោយយុត្តិធម៌ មិនរើសអើង គោរព និងស្មើភាពគ្នានៅកន្លែងធ្វើការ។ ថែរក្សា និងអនុវត្តយន្តការប្តឹងតវ៉ាសម្រាប់បុគ្គលិកគម្រោង ដូចដែលបានកំណត់ក្នុងនីតិវិធីគ្រប់គ្រងការងារ (LMP) និងស្របតាម ESS2។ ធ្វើបច្ចុប្បន្នភាពនីតិវិធីគ្រប់គ្រងការងារ (LMP) ប្រសិនបើមានការផ្លាស់ប្តូរក្នុងការរៀបចំ ការអនុវត្តសកម្មភាព និង/ឬហានិភ័យរបស់គម្រោង។ | នីតិវិធីគ្រប់គ្រងការងារត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោងត្រូវបានអនុម័ត ហើយត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |
| ESS 3៖ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការគ្រប់គ្រង និងការទប់ស្កាត់ការបំពុល | | | |
| 3.1 | **ផែនការគ្រប់គ្រងកាកសំណល់អេឡិចត្រូនិច**<br>អនុម័ត និងអនុវត្តក្រមប្រតិបត្តិបរិស្ថាន (ECOP) របស់គម្រោងសម្រាប់ការគ្រប់គ្រង និងការចោលសំណល់អេឡិចត្រូនិច ដូចដែលបានកំណត់នៅក្នុង | ត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោងត្រូវបានអនុម័ត ហើយ | លេខាធិការដ្ឋាន គ.ជ.អ.ប |

DRAFT FOR CONSULTATIONS



Confidential

| វិធានការ ឬសកម្មភាព | | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដើម្បីគ្រប់គ្រងការចោលឧបករណ៍បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) ដែលទទួលបានមូលនិធិពីគម្រោង។<br><br>បន្តការអនុវត្តឧបករណ៍រក្សាសុវត្ថិភាពបរិស្ថាន និងសង្គម ដែលបានកំណត់ក្នុងគម្រោងអាហារូបត្ថម្ភ - ទី១ (ផែនការគ្រប់គ្រងកាកសំណល់សុខាភិបាល) ដើម្បីគ្រប់គ្រងហានិភ័យបន្ថែមនៃការបង្កើតកាកសំណល់ថែទាំសុខភាពដែលមានសក្តានុពលដោយសារសកម្មភាពផ្សព្វផ្សាយក្រោមគម្រោងអាហារូបត្ថម្ភ (ទី២)។ | ត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | |
| 3.2 | **ប្រសិទ្ធភាពនៃប្រើប្រាស់ធនធាន និងការគ្រប់គ្រង និងការទប់ស្កាត់ការបំពុល**<br>ដាក់បញ្ចូលនូវលក្ខខណ្ឌនៃការប្រើប្រាស់ថាមពលតិចទៅក្នុងលក្ខខណ្ឌបច្ចេកទេសលទ្ធកម្មឧបករណ៍អេឡិចត្រូនិច។ ការដាក់បញ្ចូលនេះ គឺអនុលោមតាមគោលការណ៍ណែនាំស្តីពីសុខភាព និងសុវត្ថិភាពបរិស្ថាន (EHSGs) នៅក្នុងសៀវភៅណែនាំប្រតិបត្តិការ (OM) របស់គម្រោង។ | មុននឹងបញ្ជូនឯកសារលទ្ធកម្មនៃឧបករណ៍ ICT ទៅក្នុង STEP របស់ធនាគារពិភពលោក | លេខាធិការដ្ឋាន គ.ជ.អ.ប |
| **ESS 4: សុខភាព និងសុវត្ថិភាពសហគមន៍** | | | |
| 4.1 | **ការគ្រប់គ្រងហានិភ័យសុខភាព និងសុវត្ថិភាពសហគមន៍** | ត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |

DRAFT FOR CONSULTATIONS



Confidential

| វិធានការ ឬសកម្មភាព | | គ្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| | អនុម័ត និងអនុវត្តវិធានការ និងសកម្មភាពដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យជាក់លាក់ចំពោះសហគមន៍ដែលទាក់ទងនឹងសកម្មភាពគម្រោង រួមទាំងវិធានការទប់ស្កាត់ការឆ្លង COVID-19 ហានិភ័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន ឬការបៀតបៀនផ្លូវភេទ (SEA/SH) អំពើហិង្សាប្រឆាំងនឹងកុមារ ដូចដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ។ | ត្រូវបានអនុម័ត ហើយត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | |
| **ESS 7: ជនជាតិដើមភាគតិច** | | | |
| 7.1 | **ការចូលរួមប្រកបដោយបរិយាប័ន្ន**<br>អនុម័ត និងអនុវត្តបទប្បញ្ញត្តិនានពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) សម្រាប់ការអនុវត្តគម្រោង ដែលមានវត្តមានជនជាតិដើមភាគតិចស្របតាម ESS7 និងក្នុងលក្ខណៈដែលអាចទទួលយកបានពីធនាគារ។ វិធានការពិសេសរួមមាន: i) ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងសកម្មភាពផ្សព្វផ្សាយនានា ii)ការអនុវត្តសកម្មភាពគម្រោងសមស្របតាមវប្បធម៌ និងសង្គមរបស់ជនជាត់ដើមភាគតិច iii) យន្តការដោះស្រាយបណ្តឹងតវ៉ានានា ដែលមានសុវត្ថិភាព និងមានលក្ខណៈងាយស្រួលអនុវត្តសម្រាប់ជនជាត់ដើមភាគតិច និង iv) វិធានការសុខភាពសាធារណៈក្នុងពេលមានកូវីដ-១៩។ | ត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោងត្រូវបានអនុម័ត ហើយត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |
| **ESS 10: ការចូលរួម និងការផ្សព្វផ្សាយព័ត៌មានដល់អ្នកពាក់ព័ន្ធ** | | | |

DRAFT FOR CONSULTATIONS

| វិធានការ ឬសកម្មភាព | | គ្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| 10.1 | **ការអនុវត្តការចូលរួមរបស់អ្នកពាក់ព័ន្ធ**<br>អនុវត្តផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) របស់គម្រោង ដើម្បីធានាឱ្យមានបរិយាប័ន្ន អាចទទួលយកបាន និងការចូលរួមគោរពនូវវប្បធម៌ និងសង្គមរបស់ជនជាតើដើមភាគតិច រួមទាំងសមាជិកសហគមន៍ ក្នុងគោលបំណងអនុវត្តសកម្មភានានារបស់គម្រោង។ ផ្សព្វផ្សាយព័ត៌មាននានាដល់ភាគីពាក់ព័ន្ធក្នុងការអនុវត្តគម្រោងឱ្យបានទាន់ពេលវេលា និងអាចឱ្យអ្នកពាក់ព័ន្ធទាំងនោះអាចទួលយក និងប្រើប្រាស់បាន។ | ត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោងត្រូវបានអនុម័ត ហើយត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |
| 10.2 | **យន្តការដោះស្រាយ និងឆ្លើយតបបណ្ដឹងតវ៉ា**<br>ថែរក្សា និងពង្រឹងការអនុវត្តយន្តកាដោះស្រាយ និងរឆ្លើយតបទៅនឹងបណ្ដឹងតវ៉ានានាពាក់ព័ន្ធនឹងការអនុវត្តគម្រោង (FGRM) ដូចដែលបានពិពណ៌នានៅក្នុងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)។ | ត្រូវបានអនុម័តដោយគម្រោងនៅពេលគម្រោងត្រូវបានអនុម័ត ហើយត្រូវបានអនុវត្តពេញមួយវដ្តនៃគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |
| **ការគាំទ្រការអភិវឌ្ឍសមត្ថភាព (ការបណ្ដុះបណ្ដាល)** | | | |
| CS.1 | ផ្ដល់ការគាំទ្រផ្នែកសមត្ថភាព និងការបណ្ដុះបណ្ដាលដល់ស្ថាប័នអនុវត្តគម្រោងទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ រួមទាំងរដ្ឋបាលឃុំ សង្កាត់ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមរបស់គម្រោង ដែលរួមមាន ៖<br>• ការគ្រប់គ្រងហានិភ័យផ្នែកបរិស្ថាន និងសង្គម ដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) | មុនពេលជ្រើសរើសបុគ្គលិក និងរក្សាការអនុវត្តក្នុងអំឡុងពេលអនុវត្តគម្រោង | លេខាធិការដ្ឋាន គ.ជ.អ.ប |

DRAFT FOR CONSULTATIONS

| វិធានការ ឬសកម្មភាព | | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នអនុវត្ត |
|---|---|---|---|
| | • ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការចូលរួមផ្នែកសង្គម ដូចមានកំណត់ក្នុងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) និងក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF)<br>• ការគ្រប់គ្រងហានិភ័យទាក់ទងនឹងការងារ រួមទាំងសុខភាព និងសុវត្ថិភាព ដូចដែលបានកំណត់នៅក្នុងនីតិវិធីគ្រប់គ្រងការងារ (LMP)<br>• ការគ្រប់គ្រងហានិភ័យសុខភាព និងសុវត្ថិភាពសហគមន៍ រួមទាំងការការពារ COVID-19 ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន ឬការបៀតបៀនផ្លូវភេទ (SEA/SH) អំពើហឹង្សាប្រឆាំងនឹងកុមារ (VAC) ដូចដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) និងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP)<br>• យន្តការដោះស្រាយ និងឆ្លើយតបបណ្តឹងតវ៉ា និងដំណើរការអនុវត្តយន្តការ | | |

DRAFT FOR CONSULTATIONS



Confidential